BMI0032

# សម្ភាសន៍ជាមួយឈ្មោះ តិប ធីម ភេទស្រី អាយុ៤៧ឆ្នាំ

មុខងារជំនាន់ខ្មែរក្រហម“ពេទ្យ”

មុខងារបច្ចុប្បន្ន“កសិករ”

ស្រុកកំណើតនៅភូមិម៉ារើន ឃុំដា ស្រុកក្រចេះ ខេត្តក្រចេះ

រស់នៅភូមិដូន ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ សោម ប៊ុនថន

០០:៥៦:៣១

២៧ទំព័រ

ប៊ុនថនៈ ជាដំបូងចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអីដែរ?

ធីមៈ ឈ្មោះ តិប ធីម ។

ប៊ុនថនៈ តិប ធីម?

ធីមៈ ចាស ។

ប៊ុនថនៈ អាយុប៉ុន្មានមីង?

ធីមៈ ៤៧ហើយ ។

ប៊ុនថនៈ មីងមានស្រុកកំណើតនៅណា?

ធីមៈ ស្រុកកំណើតនៅក្រចេះ ។

ប៊ុនថនៈ ភូមិអីដែរ?

ធីមៈ ភូមិម៉ារើន ។

ប៊ុនថនៈ ឃុំ?

ធីមៈ ឃុំដា ។

ប៊ុនថនៈ ឃុំដា ស្រុកអីវិញ?

ធីមៈ ស្រុកក្រចេះ ។

ប៊ុនថនៈ ចឹងពូនៅក្រចេះដែរ?

ធីមៈ នៅក្រចេះ ។

ប៊ុនថនៈ មីងមានបងប្អូនប៉ុន្មាននាក់?

ធីម៖	មានបងប្អូន១០នាក់ ។

ប៊ុនថន៖	មីងកូនទីប៉ុន្មាន?

ធីម៖	ខ្ញុំកូនទី៨ទី៩ហើយ ។

ប៊ុនថន៖	ចឹងនៅក្រចេះហ្នឹងមីងចូលរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ធីម៖	សម័យបីឆ្នាំហ្នឹងថ្នាក់ទី៣ ។

ប៊ុនថន៖	មីងរៀនសាលាក្នុងភូមិ?

ធីម៖	សាលាក្នុងភូមិ ។

ប៊ុនថន៖	ចឹងនៅពេលឈប់រៀនមីងមកនៅណាទៀត?

ធីម៖	ដល់ពេលឆ្នាំ៧៨នេះ គេរើសកុមារមកភ្នំពេញ២០០នាក់ហ្នឹង ក៏ដោយមកតាមគេមក ។

ប៊ុនថន៖	រើសកុមារហ្នឹងគេ រើសនៅក្នុងភូមិច្រើននាក់ដែរ?

ធីម៖	គេរើសក្នុងស្រុកតែម្តង២០០នាក់ហ្នឹង ។

ប៊ុនថន៖	ស្រុកក្រចេះហ្នឹងតែម្តង?

ធីម៖	ចាស!ក្នុងមួយឃុំចឹងគេយកជាង១០នាក់ចឹងទៅណាស់ ។

ប៊ុនថន៖	ចឹងកាលមកហ្នឹងឪពុកម្តាយមីងដឹងទេ?

ធីម៖	អត់ដឹងទេ ដំបូងគេឲ្យទៅរៀននៅមន្ទីរពេទ្យ គេឲ្យទៅរៀនពេទ្យ ។

ប៊ុនថន៖	បាទ ។

ធីម៖	រៀនពេទ្យហ្នឹងពេទ្យឃុំឆ្ងាយពីផ្ទះណាស់ ដល់ពេលគេត្រូវរើសកុមារមកភ្នំពេញគាត់អត់ដឹង គាត់អត់ដឹងទេ គេជ្រើសមកភ្នំពេញក៏មកភ្នំពេញគេទៅគាត់ដឹងដំណឹងក្រោយ ។

ប៊ុនថន៖	ចឹងមីងមកហើយបានគាត់ដឹង?

ធីម៖	ចាស ។

ប៊ុនថន៖	រៀនពេទ្យហ្នឹងបានយូរទេ?

ធីម៖	រៀនពេទ្យហ្នឹងបានមួយឆ្នាំដែរ ។

ប៊ុនថន៖	រៀនហ្នឹងរៀនរបៀបម៉េចវិញ?

ធីម៖	រៀនដាក់ស្តែង រៀនចាក់អីតែម្តងហ្នឹង រៀនទ្រឹស្តីរៀនចាក់តែម្តង ។

ប៊ុនថន៖	ចឹងមីងរាល់ថ្ងៃចេះចាក់ដែរ?

ធីម៖	ចេះដែរព្យាបាលកូនចៅនៅផ្ទះ ។

ប៊ុនថន៖	បង្រៀនហ្នឹងមានគ្រូមានអីដែរ?

ធីម៖	មានគ្រូបង្រៀនគេនៅមន្ទីរពេទ្យតែម្តង ។

ប៊ុនថនៈ រៀននៅមន្ទីរពេទ្យណា?

ធីមៈ រៀននៅមន្ទីរពេទ្យឃុំដាតែម្តង ។

ប៊ុនថនៈ កាលចូលរៀនមានច្រើនទេមីង?

ធីមៈ រៀនច្រើនដែរ រៀនយូរហើយវាចង់ភ្លេច យូរហើយតាំងពី៧៨នោះ ។

ប៊ុនថនៈ ចឹងមានគេណែនាំឲ្យមើលថ្នាំអីដែរ គេមានណែនាំថ្នាំអីដែរ?

ធីមៈ មើលចេះបានតិចតួច កាលហ្នឹងគេមិនសូវរៀនអត់គ្លេសដូចយើង ដូចថាគេរៀនតែប្រវត្តិថ្នាំតែម្តង គេមិនរៀនអង់គ្លេសដូចក្មេងឥឡូវដាក់ស្អឹមកក៏វាចេះវាដឹង ។

ប៊ុនថនៈ រៀនចំណាំថ្នាំប្តូមួយយ៉ាងម៉េច?

ធីមៈ យើងរៀនថ្នាំអំពូល ថាថ្នាំនេះត្រូវព្យាបាលអានេះចឹងទៅណាស់ ។

ប៊ុនថនៈ ចឹងរៀនហ្នឹងមានព្យាលបាលអ្នកជំងឺអីទេ?

ធីមៈ ចាស!ព្យាបាលតាមមន្ទីរពេទ្យ ជំនាន់ហ្នឹងគេរៀនទៅដូចជាយើងដាក់ស្តែងតែម្តងមិនដូចយើងឥឡូវរៀនជាប់ផ្នែកបណ្ឌិតអីបានទៅធ្វើពេទ្យចឹងបាន ជំនាន់យើងបីឆ្នាំហ្នឹងរៀនចឹងឯង រៀនដាក់ស្តែងតែម្តង ។

ប៊ុនថនៈ ចឹងមីងរៀនមួយឆ្នាំចេះ?

ធីមៈ ចាស ។

ប៊ុនថនៈ ចឹងមួយឆ្នាំចេះអាចព្យាបាលបាន?

ធីមៈ ព្យាបាលបានតិចតួច ។

ប៊ុនថនៈ ចឹងកាលរើសមកភ្នំពេញហ្នឹងស្ម័គ្រចិត្តឬមួយរើស?

ធីមៈ គេរើសតែម្តង គេចុចឈ្មោះយើងរើសមកមិនដឹងខ្លួន ។

ប៊ុនថនៈ និយាយថា គេរើសមកហ្នឹងមីងចង់មកដែរ ចង់មកមើលភ្នំពេញ?

ធីមៈ ហ្នឹងឯងចង់មកមើលភ្នំពេញអីចឹងណាស់យើងមិនដែលឃើញភ្នំពេញផង ។

ប៊ុនថនៈ ចឹង៧៨មីងមកភ្នំពេញ?

ធីមៈ ចាស ។

ប៊ុនថនៈ មីងមកនៅកន្លែងណាវិញ?

ធីមៈ មកនៅទួលគោក ។

ប៊ុនថនៈ កាលហ្នឹងគេហៅអីវិញមីង?

ធីមៈ គេហៅទួលគោកចឹងឯង ។

ប៊ុនថនៈ តែយើងមកកន្លែងធ្វើការ?

ធីម: ភ្ញៀវស្ថានទូត?

ប៊ុនថន: ស្ថានទូត?

ធីម: ចាស!ស្ថានទូតអឺរ៉ុប នៅទួលគោកហ្នឹងស្ថានទូតអារ៉ុបហ្នឹងតែម្ដង ។

ប៊ុនថន: ស្ថានទូតប្រទេសអីវិញមីង?

ធីម: ពួកអឺរ៉ុប ។

ប៊ុនថន: ចឹងកាលមីងមកហ្នឹងមានឃើញជនជាតិទេ?

ធីម: ឃើញតើ ឃើញពួកស្បែកខ្មៅពួកសក់រួញក្រញ៉ុលៗហ្នឹង ។

ប៊ុនថន: គ្នាច្រើនទេមីង?

ធីម: គ្នា១៨នាក់ ។

ប៊ុនថន: ចឹងមីងនៅក្នុងស្ថានទូតហ្នឹងធ្វើអីទៅ?

ធីម: នៅហ្នឹងអត់មានធ្វើអីផង កាលហ្នឹងនៅតូចៗដូចថាគេយកមកនៅអីចឹងទៅណាស់ មីងលី ជាងគាត់យកមកនៅចឹងទៅណាស់ នៅមើលកូនគាត់ចឹងទៅ គាត់មានកូនគាត់ធ្វើការ កន្លែងភ្ញៀវហ្នឹងនោះ ។

ប៊ុនថន: មើលកូនឲ្យពីណា?

ធីម: កូន មីងលី ជាងយើងនេះ ។

ប៊ុនថន: លី ជាង?

ធីម: មីងលី ពូជាងស្គាល់គ្នា ។

ប៊ុនថន: កាលហ្នឹងគាត់ធ្វើអី?

ធីម: កាលហ្នឹងគាត់ទទួលផ្នែកក្រសួងការងារបរទេស ។

ប៊ុនថន: និយាយថានៅកន្លែងហ្នឹងមានអគារធំទេ?

ធីម: អគារធំៗមួយជាន់ពីរជាន់បីជាន់អីដែរ នៅទួលគោក ។

ប៊ុនថន: កន្លែងធ្វើការឬជាកន្លែងស្នាក់នៅ?

ធីម: ចាស!ជំនាន់ហ្នឹងដូចថាម្ចាស់គេដកគ្នាទៅនៅកន្លែងនេះកន្លែងនោះចឹងទៅអីហើយទំនេរផ្ទះ ចឹងទៅគេបង្កើតជាកន្លែងស្អីមួយចឹងទៅណាស់ ។

ប៊ុនថន: ចឹងកាលហ្នឹងពូចៀមមីងលីហ្នឹងគាត់ធ្វើអី?

ធីម: ពូចៀម មីងលីហ្នឹងគាត់ទទួលក្រសួងការបរទេស គាត់នៅ«ប-១» ។

ប៊ុនថន: គាត់ប្រធានមន្ទីរហ្នឹងតែម្ដង?

ធីម: ចាស ។

ប៊ុនថន:	ចឹងមីងផ្ញើនៅហ្នឹងយូរទេ មើលកូនឲ្យគាត់ហ្នឹង?

ធីម:	កាលហ្នឹងមកបានបីខែទទួលយើងសង្គ្រាមចឹងទៅ ប្រាប់មីងថាចង់ទៅផ្ទះតែមិនស្គាល់ផ្លូវ មិនដឹងជាទៅតាមណាកុំអីទៅផ្ទះបាត់ហើយ ។

ប៊ុនថន:	បាទ ។

ធីម:	តែគេថាទៅៗយួនអាក ចុះភ័យនៅក្មេងដែលវាឆ្មោតមកតាមគេមក ។

ប៊ុនថន:	កាលហ្នឹងអាយុប៉ុន្មានមីង?

ធីម:	អាយុ១៤-១៥ដែលហើយកាលហ្នឹង ។

ប៊ុនថន:	ចឹងកាលមីងរត់ជំបូងរត់តាមផ្លូវណា?

ធីម:	រត់ជំបូងយើងរត់ពីភ្នំពេញហ្នឹងមកកំពង់ឆ្នាំង មកបាត់ដំបងមកយើងស្វាយសុីសាផុនអីហ្នឹង មកផ្លូវប៉ោយប៉ែតហ្នឹងហើយចេញមកច្រកម៉ាឡៃហ្នឹងវិញ ។

ប៊ុនថន:	ច្រកម៉ាឡៃ?

ធីម:	ចាស!ច្រក៧៩កន្លែងខ្ញុំនៅ គាមតែទៅឆ្ងាយណាស់តាមប៉ៃលិនអីនោះដើរតែរហូតហ្នឹង ចេះតែនៅតាមគេទៅ ។

ប៊ុនថន:	ចឹងមីង លី ពូចៀមហ្នឹងគាត់ទៅណា?

ធីម:	គាត់ទៅជាមួយគ្នាតាមតែភ្ញៀវហ្នឹងទាំងអស់ គាត់នៅកន្លែងក្រសួងការបរទេសហ្នឹងនោះ ។

ប៊ុនថន:	ចឹងភ្ញៀវរត់ទៅណាវិញ?

ធីម:	ភ្ញៀវរត់ជាមួយយើង យើងទៅណាគាត់ទៅហ្នឹង ទើបជូនទៅ១០២ហ្នឹងដីម៉ាឡៃទើបជូនទៅថៃ ទៅតាមថៃ ។

ប៊ុនថន:	ចឹងជូនគាត់ទៅឆ្នាំណាមីង?

ធីម:	ឆ្នាំ៧៩ហ្នឹង ។

ប៊ុនថន:	គាត់មកដល់ហ្នឹងជូនទៅហ្នឹង?

ធីម:	ចាស ។

ប៊ុនថន:	ចឹងកាលមកដល់ហ្នឹងដំបូងម៉ាឡៃហ្នឹងមានផ្លូវមានអីទេ?

ធីម:	មានតែម៉ាច្រកដើរអត់មានផ្លូវធំទេ ។

ប៊ុនថន:	អត់មានផ្លូវធំទេ?

ធីម:	អត់សុទ្ធតែព្រៃ សុទ្ធតែព្រៃតែម្តងអត់មានភូមិមានអីទេត្រង់នេះនោះឆ្នាំ៧៩ ។

ប៊ុនថន:	ព្រៃក្រាស់តែម្តង?

ធីមៈ ហ្នឹងហើយព្រៃក្រាស់តែម្តងដើមឈើធំៗ ។

ប៊ុនថនៈ ចឹងមកនៅយ៉ាងម៉េចទៅមឹងមានតែព្រៃអត់មានផ្ទះអីចឹងណាស់?

ធីមៈ យើងចេះតែឆ្កាប្រក់ស្បៅប្រក់អីនៅទៅអាអូន ។

ប៊ុនថនៈ មកច្រើនទេមឹង កាលរត់មកហ្នឹង?

ធីមៈ មកច្រើនណាស់រាប់ពាន់រាប់ម៉ឺននាក់នោះ ។

ប៊ុនថនៈ មកពីស្វាយមកពីអីហ្នឹងមឹង?

ធីមៈ ចាស!មនុស្សច្រើនណាស់រាប់ពាន់រាប់ម៉ឺននាក់នោះ ។

ប៊ុនថនៈ មកតែប្រជាជនលាយគ្នាមឹង?

ធីមៈ លាយគ្នាថាយើងក្នុងជំរំអន្តុភាពចឹងទៅមានកូនមានចៅ ។

ប៊ុនថនៈ មកច្រើនចឹងនិយាយថាយើងមកតាមគ្នាប្តូមួយយ៉ាងម៉េច?

ធីមៈ មកតាមអន្តុភាពកាលជំនាន់ហ្នឹងសម័យបីឆ្នាំហ្នឹងមានអន្តុភាពគេ ។

ប៊ុនថនៈ បាទ ។

ធីមៈ មានកន្លែងមន្ទីរអន្តុភាពគេចឹងទៅ ដូចថាយើងអន្តុភាពណាយើងទៅតាមអន្តុភាពហ្នឹងទៅ ។

ប៊ុនថនៈ មកច្រើនចឹងបានអីហូបទៅ?

ធីមៈ ចុះកាលហ្នឹងអន្តរកាកបាទគេជួយយើងនោះ ។

ប៊ុនថនៈ និយាយតាមផ្លូវមកមឹង?

ធីមៈ តាមផ្លូវមកយើងដាក់អន្តរពីយើងមក ដាក់ទៃស្តាយដាក់អន្តរ ។

ប៊ុនថនៈ នៅតាមផ្លូវមានអ្នកខ្លះស្លាប់ដោយសារអត់អីទេមឹង?

ធីមៈ មាន ឈឺដាច់បាយដាច់ទឹកទៅ និយាយស្លាប់ច្រើន ។

ប៊ុនថនៈ ចឹងមឹងមកដល់ដំបូងម៉ាឡៃហ្នឹងមានអ្នកនៅពីមុនមកទេ?

ធីមៈ អត់មានទេ ។

ប៊ុនថនៈ សុទ្ធព្រៃតែម្តង?

ធីមៈ ចាស! កាលហ្នឹងមានកន្លែងថៃក្រហមដែលគេរស់នៅ គេហៅអិន តាំណាស់ ពួកអិន តាំនៅម៉ាកន្លែងៗ ខ្ញុំកាលហ្នឹងនៅកន្លែងអិន តាំដែរ ។

ប៊ុនថនៈ អិន តាំនៅណាវិញ?

ធីមៈ អិន តាំគេចេញទៅ នៅនេះយើងគីឡូ៣០នេះ អិន តាំគេចេញទៅនាំគ្នាទៅនៅរោងអិន តាំហ្នឹង៦៨ ។

| | |
|---|---|
| ប៊ុនថន៖ | ចឹងកាលពីមុនមានអ្នកនៅដែរ? |
| ធីម៖ | ចាស!មានតែពួកថៃហ្នឹង ពួកថៃក្រហមយើងនៅតាមរោងថៃចឹងទៅ ។ |
| ប៊ុនថន៖ | ឆ្ងាយពីហ្នឹងទេ គីឡូ៣០ហ្នឹង? |
| ធីម៖ | ជិតរាំងធ្លាក់ ។ |
| ប៊ុនថន៖ | ប្រហែលជាប៉ុន្មានគីឡូពីហ្នឹង? |
| ធីម៖ | ទៅពីហ្នឹងឆ្ងាយដែលជាប់៥០គីឡូវ៦០គីឡូវដែលដឹង ឆ្ងាយដែលហ្នឹងណាស់ ។ |
| ប៊ុនថន៖ | ចឹងមីងទៅនៅ ទៅនៅផុតហ្នឹងទៀតទៅនៅផុតម៉ាខ្សែទៀត? |
| ធីម៖ | នៅច្រើនណាស់ នៅម៉ាជំនាហ្នឹងរហូតដើរតែនៅដើរតែនេះដើរទៅត្រង់នោះ ចុះយើងនៅរបៀបថាអ្នកជម្លៀសនោះណាស់ ។ |
| ប៊ុនថន៖ | បាទ ។ |
| ធីម៖ | យើងមាននៅតែមួយកន្លែងណា ។ |
| ប៊ុនថន៖ | ចឹងកាលមីងមកដល់ដំបូងមីងមាននៅនេះទេ? |
| ធីម៖ | ទៅពីហ្នឹងបកមកនៅហ្នឹងវិញដដែរ ទៅមកៗតែហ្នឹង ។ |
| ប៊ុនថន៖ | នៅយូរទេថៃក្រហមហ្នឹង? |
| ធីម៖ | នៅជាប់មួយឆ្នាំដែរ ។ |
| ប៊ុនថន៖ | ចឹងដល់ឆ្នាំ៨០មីងមកនេះវិញ? |
| ធីម៖ | ចុងឆ្នាំ៧៩-៨០ហ្នឹងបកទៅឧត្តរមានជ័យ គេយកទៅដល់មានជ័យនោះ ។ |
| ប៊ុនថន៖ | យ៉ាងម៉េចបានគេដកទៅឧត្តរមានជ័យវិញ? |
| ធីម៖ | អត់ដឹងដែរ ។ |
| ប៊ុនថន៖ | ទៅច្រើនទេ កាលហ្នឹង? |
| ធីម៖ | ចាស!ទៅច្រើន ។ |
| ប៊ុនថន៖ | ពួអីទៅឧត្តរមានជ័យដែរ? |
| ធីម៖ | គេនោះខាងទន្លេល្អៅ ។ |
| ប៊ុនថន៖ | ទន្លេល្អៅ? |
| ធីម៖ | ចាស!ខាងទល់ដែនលាវមកពីខាងនោះវិញ ខាងរតនៈគីរីវិញខ្ញុំ កាលមុនខ្ញុំនៅរតនៈគីរីនោះ "លាយសម្តីប្តី" ។ |
| ប៊ុនថន៖ | បាទ ។ |
| ធីម៖ | ប្តីគាត់និយាយ" ក្រោយមកទៀតបានខ្ញុំមកនៅនេះវិញ ។ |

ប៊ុនថន: ចឹងមីងដកទៅអន្លង់វែងហ្នឹងខាងណាកំលាំងតស៊ូដកទៅ?

ធីម: ចាស!កំលាំងតស៊ូទៅជាអន្តភាពចឹងទៅ កាលជំនាន់ហ្នឹងយើងតា ម៉ុកនោះ តា ម៉ុកយកកំលាំងហ្នឹងទៅ ។

ប៊ុនថន: យកទៅច្រើនទេ?

ធីម: ច្រើន ច្រើនដែលកាលហ្នឹង ។

ប៊ុនថន: ទៅហ្នឹងជិះឡានឬមួយថ្មើរជើង?

ធីម: ជិះឡាន ភាគច្រើនគឺក្មេង ។

ប៊ុនថន: ទៅចេញច្រកតាមណាវិញមីង?

ធីម: ទៅតាមដីថៃនេះ ។

ប៊ុនថន: ចូលទៅថៃហើយបានទៅនោះ?

ធីម: ចាស!ចូលតាមដីថៃ ផ្លូវយើងមិនមានផ្លូវទៅទេ ។

ប៊ុនថន: ចឹងមីងមកនៅនេះនៅមិនបានយូរទេម៉ាឡៃ?

ធីម: ចាស ។

ប៊ុនថន: ចឹងមីងនៅប្រហែលជាបានរយៈពេលប៉ុន្មានទៅ?

ធីម: នៅម៉ាឡៃហ្នឹងមិនដឹងជាបានប៉ុន្មានខែទេដូចជាភ្លេចទៅ នៅមិនយូរប៉ុន្មានទេនៅបានមួយរយៈបីបួនខែប៉ុណ្ណឹង ។

ប៊ុនថន: ចឹងដកទៅហ្នឹងទៅតែស្រីៗទេឬមួយមានប្រុសលាយគ្នា?

ធីម: មាន តែភាគច្រើនគេយកទៅកាលហ្នឹងច្រើនតែអន្តភាពកុមារ៦០នាក់ ។

ប៊ុនថន: ចឹងមីងទៅដល់ឧត្តរមានជ័យហ្នឹងមីងទៅនៅណាវិញ?

ធីម: ទៅដល់ឧត្តរមានជ័យទៅនៅភ្នំអីទេ ភ្លេចអាភ្នំហ្នឹងទៀតទៅនៅតែលើភ្នំហ្នឹង ភ្នំដងរែកហ្នឹងឯង ។

ប៊ុនថន: ចឹងភ្នំដងរែកហ្នឹងកាលទៅដល់ដំបូងហ្នឹងមានមនុស្សទៅនៅហ្នឹងទេមីង?

ធីម: ភ្នំដងរែកទៅដល់ដំបូងមានមនុស្សគេនៅហ្នឹង មានអន្តភាពទ័ពមីងៗអីប្រជាជនអីនៅហ្នឹងពេញ ដល់គេកើតភូមិកើតអីពេញហ្នឹងហើយ ។

ប៊ុនថន: ចឹងមីងទៅនៅអន្តភាពដដែលឬគេបំបែកយ៉ាងម៉េចមីង?

ធីម: ទៅកាលហ្នឹងគេបំបែកមីងលីនេះគេឲ្យទៅនៅកន្លែងមន្ទីរកុមារ ទៅនៅរៀនអីចឹងទៅ ។

ប៊ុនថន: បាទ ។

ធីម: ឲ្យយើងរៀន យើងអាយុប៉ុណ្ណឹងពេញរៀនហើយ ។

ប៊ុនថន៖ ចឹងមីងមានបានទៅរៀនទេ?

ធីម៖ រៀន ។

ប៊ុនថន៖ រៀនអក្សរខ្មែរយើងហ្នឹង?

ធីម៖ រៀនខ្មែរយើងហ្នឹងណាស់ ។

ប៊ុនថន៖ មានគ្រូបង្រៀនអីចឹងទៅ?

ធីម៖ ចាស!មានគ្រូបង្រៀន ។

ប៊ុនថន៖ ចឹងកុមារទៅពីហ្នឹងទៅរៀនទាំងអស់ឬមួយយ៉ាងម៉េច?

ធីម៖ ចាស!រៀនទាំងអស់ ។

ប៊ុនថន៖ ចឹងក្រៅពីរៀនធ្វើអីទៀតមីង?

ធីម៖ កាលហ្នឹងរៀនផងគេបង្កើតក្រុមសិល្បៈ ខ្ញុំចូលក្រុមសិល្បៈហ្នឹងគេទៅ ។

ប៊ុនថន៖ រៀនសិល្បៈ?

ធីម៖ ចាស ។

ប៊ុនថន៖ និយាយថាសិល្បៈហ្នឹងមានច្រើនដូចមានសម្ដែងមានច្រៀងអីទេ?

ធីម៖ ចាស!មានសម្ដែងច្រៀងអីហ្នឹងណាស់ ដូចថាយើងដើរសម្ដែងលេងតាមអង្គភាពទ័ព អង្គភាពដូចថាប្រជាជនមីង១ចង់មើលចង់អីចឹងទៅសម្ដែងច្រៀងរាំលេង រាំរបាំអីចឹងទៅណាអូន ។

ប៊ុនថន៖ ចឹងគាត់ខាងអគ្គីសនីពូអី?

ធីម៖ ហ្នឹងហើយ ។

ប៊ុនថន៖ ចឹងមីងលេងទេ ខាងសិល្បៈហ្នឹង?

ធីម៖ សិល្បៈហ្នឹងលេងយូរដែលជាប់មួយឆ្នាំដែរ ៨០-៨២និង៨២ ។

ប៊ុនថន៖ កាលហ្នឹងនៅក្មេងល្អង់ហ្នឹង៨១-៨២?

ធីម៖ ចាស!ខ្ញុំឆ្នាំរោង ។

ប៊ុនថន៖ ចឹងដើរលេងតែកន្លែងកំលាំងតស៊ូហ្នឹងទេមីង?

ធីម៖ ចាស ។

ប៊ុនថន៖ ដើរលេងឆ្ងាយៗដល់ខេត្តអីផ្សេងទេ?

ធីម៖ អត់មានខេត្តទេ មានតែអង្គភាពចឹងយើងមានតែអង្គភាពត្រង់ហ្នឹង១១ចឹងទៅណាស់ជុំវិញចឹងទៅមិនមានដល់ខេត្តទេ ។

ប៊ុនថន៖ បាទ ។

ធីមៈ ចុះយើងខ្មែរក្រហមមិនមានខេត្តអីគេទេ មានតែអន្តភាព ។

ប៊ុនថនៈ ចឹងអន្តភាពសិល្បៈហ្នឹងមានប៉ុន្មាននាក់មីង?

ធីមៈ អន្តភាពសិល្បៈកាលហ្នឹងមិនដឹងជាប៉ុន្មានទេ ប្រហែលជា៥០នាក់ដែរ គ្នាច្រើនដែលហ្នឹងណាស់ ។

ប៊ុនថនៈ តែមានស្រីមានប្រុសទេ?

ធីមៈ ចាស!មានស្រីមានប្រុស មានចាស់ៗមានក្មេងៗចឹងទៅ ។

ប៊ុនថនៈ ចឹងខាងសិល្បៈហ្នឹងនៅខាងទ័ពដែលទេ?

ធីមៈ នៅខាងទ័ព ។

ប៊ុនថនៈ ចឹងអ្នកគ្រប់គ្រងទៅពីនេះឬគេនៅខាងនោះ?

ធីមៈ អន្តភាពយើងអ្នកទៅពីនេះដែរ ខ្ញុំនៅជាប់តែអន្តភាពហ្នឹងរហូត ។

ប៊ុនថនៈ ថាមីងលីហ្នឹង?

ធីមៈ ចាស ។

ប៊ុនថនៈ នៅគ្រប់គ្រងហ្នឹង?

ធីមៈ ចាស ។

ប៊ុនថនៈ ចឹងគាត់មានឈ្មោះអីពេញមីងលី?

ធីមៈ មីងលីហ្នឹងមិនដឹងជាត្រកូលគាត់ស្អី ។

ប៊ុនថនៈ ចឹងផ្ទះគាត់នៅជិតនេះដែលតើ?

ធីមៈ នេះកន្លែងលាងឡានលាងម៉ូតូ ម៉ូតូមុនប៉េអ៊ឹមហ្នឹង ។

ប៊ុនថនៈ ប្រហែលជាជានីចូលហើយ ប្តីគាត់ឈ្មោះ ចៀម?

ធីមៈ ហ្នឹងហើយនៅទល់មុខប៉េអ៊ឹមហ្នឹងហើយ ។

ប៊ុនថនៈ ចឹងប្តីគាត់ឈ្មោះចៀម?

ធីមៈ ហ្នឹងហើយ ។

ប៊ុនថនៈ ស្អីចៀម?

ធីមៈ លី ។

ប៊ុនថនៈ លី ចៀម?

ធីមៈ ប្រពន្ធគាត់ឈ្មោះមីងលី ប្តីគាត់ឈ្មោះពូចៀម ។

ប៊ុនថនៈ តែត្រកូលអីចៀម?

ធីមៈ អត់ដឹង អត់ដែលដឹងត្រកូលគាត់ផង មិនបានសួរនាំ ។

ប៊ុនថន៖ មីងទៅហ្នឹងនៅក្រោមគាត់ទៀត គាត់គ្រប់គ្រង?

ធីម៖ ចាស ។

ប៊ុនថន៖ តែលើគេគា ម៉ុក?

ធីម៖ លើគេ គា ម៉ុក ។

ប៊ុនថន៖ ចឹងនៅហ្នឹងក្រៅពីសិល្បៈក្រោយមកមីងធ្វើអីទៀតមីង?

ធីម៖ នៅដឹកជញ្ជូន នារីដឹកជញ្ជូន ។

ប៊ុនថន៖ ដឹកជញ្ជូន?

ធីម៖ ដឹងជញ្ជូនលីគ្រាប់អីហ្នឹង គេប្រើធ្វើអីក៏ធ្វើយើងនៅក្រោមបង្គាប់គេហើយ ។

ប៊ុនថន៖ ធ្វើអីខ្លះដឹងជញ្ជូនហ្នឹង?

ធីម៖ មានអីអូនលីតែគ្រាប់លីតែអី គេឲ្យយើងធ្វើពេទ្យបន្តិចបន្តួចអីចឹងទៅណាស់ ព្យាបាលអ្នករបួសអ្នកជំងឺតាមផ្លូវអីចឹងណាស់ ។

ប៊ុនថន៖ ចឹងមីងធ្លាប់ធ្វើពេទ្យចឹងគេឲ្យធ្វើពេទ្យទៅ?

ធីម៖ ចាស ។

ប៊ុនថន៖ ចឹងមីងមានចេះបើកឡានអីទេ?

ធីម៖ អត់ កាលដើរដឹកជញ្ជូនមានឡានមានអីណាដើរកាត់ព្រៃហ្នឹងតែម្តងណាស់ ។

ប៊ុនថន៖ ចឹងហូបចុកអីតយ៉ាងម៉េចដែរ?

ធីម៖ អត់អីទេ ហូបបរបូរ ។

ប៊ុនថន៖ ចឹងហូបគ្រប់គ្រាន់?

ធីម៖ ចាស!គ្រប់គ្រាន់ អង្ករទាំងឃ្លាំងៗយកហូបទៅ ។

ប៊ុនថន៖ ត្រីសាច់អីមាន?

ធីម៖ ត្រីសាច់ទាល់តែយើងរកខ្លួនឯង តែសម្បូរសត្វព្រៃហូបណាស់ នៅដងវែកសម្បូរណាស់ជំនាន់ហ្នឹហមានព្រៃនោះ ។

ប៊ុនថន៖ ចឹងចង់និយាយបកទៅក្រោយគេបង្រៀនអក្សរហ្នឹងពេលមីងមកសិល្បៈគេឈប់បង្រៀនហើយ ។

ធីម៖ ចាស!តែយើងនៅសិល្បៈហ្នឹងក៏រៀន ។

ប៊ុនថន៖ រៀនដែរ?

ធីម៖ រៀន ។

ប៊ុនថន៖ ចឹងមានឈៀតពេលរៀនអក្សរដែរ?

ធីមៈ ចាស ។

ប៊ុនថនៈ ចឹងពេលមកដឹកជញ្ជូន?

ធីមៈ ពេលមកដឹកជញ្ជូនហ្នឹងយើងឈប់រៀនហើយ ចូលវៃអាយុច្រើនហើយ១៨-១៩ឆ្នាំហើយ ។

ប៊ុនថនៈ ចឹងគ្រូបង្រៀនទៅពីណា?

ធីមៈ ខ្មែរក្រហមយើងហ្នឹង ។

ប៊ុនថនៈ ដែលរត់ពីភ្នំពេញទៅដែរ?

ធីមៈ ចាស ។

ប៊ុនថនៈ ចឹងមីងនៅកងដឹកជញ្ជូនហ្នឹងដល់ឆ្នាំណា?

ធីមៈ ដឹកជញ្ជូនដល់ឆ្នាំ៨៦ ។

ប៊ុនថនៈ ៨៦?

ធីមៈ ៨៦ មានគ្រួសារ ។

ប៊ុនថនៈ ការជាមួយពូ?

ធីមៈ ចាស ។

ប៊ុនថនៈ គេរៀបដែរ?

ធីមៈ រៀបត្រឹមត្រូវ ការត្រឹមត្រូវមានអាចារ្យអីដូចគេឯងដែរ ។

ប៊ុនថនៈ ចឹងការតែមួយគូរតើមីង?

ធីមៈ ចាស!ការតែមួយគូរ ។

ប៊ុនថនៈ ចឹងមានអាចារ្យមានមេក្រូហោភ្ញៀវអីដែរ?

ធីមៈ ចាស!មាន មានមេក្រូអីហៅភ្ញៀវដូចតែគ្នាហ្នឹង តែកាលជំនាន់ហ្នឹងគេចងដៃអីចងតិចតួចមិនដូចយើងឥឡូវទេ ៣០បាត២០បាត ។

ប៊ុនថនៈ ចឹងមីងការហើយមីងនៅអគ្គភាពដដែលឬនៅផ្ទះ?

ធីមៈ អត់ទេ ការហើយពោះធំអាបងគេហ្នឹង បងខ្ញុំទៅយកពីហ្នឹងមកនៅហ្នឹងនៅ៨៥យើងហ្នឹងនៅវត្តតាង៉ាដីថៃ ។

ប៊ុនថនៈ ចឹងការ៨៦ហ្នឹងបានយកមកពីជំរំ៨៥?

ធីមៈ ចាស ។

ប៊ុនថនៈ បងមីងគាត់ធ្វើអីវិញ?

ធីមៈ អត់ធ្វើអីទេ គាត់នៅសិល្បៈ១០២ ។

ប៊ុនថនៈ ១០២ខាងណាវិញ?

ធីមៈ ១០២នៅហ្នឹង ។

ប៊ុនថនៈ នៅម៉ាឡៃហ្នឹង?

ធីមៈ ចាស ។

ប៊ុនថនៈ ចឹង១០២ហ្នឹងសម្គាល់អត្តភាពឬយ៉ាងម៉េច?

ធីមៈ ១០២ហ្នឹងគេសម្គាល់អីទេហ្នឹងហើយសម្គាល់ដូចស្រុកមួយចឹងណាស់ដូចជាម៉ាឡៃចឹងទៅណាស់ គេដាក់១០២តែម្តងទៅ ។

ប៊ុនថនៈ ចឹង៨៦មីងមកនៅជំរំដីថៃ?

ធីមៈ ចាស ។

ប៊ុនថនៈ ចឹងកាលមីងទៅឧត្តរមានជ័យហ្នឹងមីងមានដែលវ៉ៃគ្នាជាមួយកំលាំងខាងក្នុងទេ?

ធីមៈ កាលជំនាន់ហ្នឹងវ៉ៃគ្នាតើ ។

ប៊ុនថនៈ កាលហ្នឹងមានវ៉ៃខ្លាំងទេ?

ធីមៈ កាលហ្នឹងវ៉ៃខ្លាំងណាស់ ។

ប៊ុនថនៈ ចឹងកំលាំងខាងក្នុងមានដែលវ៉ៃចូលដល់ទេ វ៉ៃចូលដល់កន្លែងមីងនៅ?

ធីមៈ អត់ដល់ផង អេដល់ណាមីងណឹង ឆ្នាំ៨៤វ៉ៃមកដល់យើងមិនរត់ ។

ប៊ុនថនៈ ចឹងមានវ៉ៃដែលមីង?

ធីមៈ វ៉ៃដែលក្មួយខ្ញុំរត់ចង់ងាប់ចង់រស់ហើយ តែកាលឆ្នាំ៨៤នោះណាស់ ។

ប៊ុនថនៈ «ស៊ីនិត» កាលឆ្នាំ៨៤នៅភ្នំពេញកំពង់តែចាប់ទាហាន?

ធីមៈ ហ្នឹងហើយចាប់ទាហានបញ្ជូនមកហ្នឹង វ៉ៃព្រំដែនហ្នឹង ។

ប៊ុនថនៈ វ៉ៃហើយមានរត់ចេញទៅកំលាំងខាងក្នុងមានដាក់នៅហ្នឹងទេ ដកចេញឬមួយក៏?

ធីមៈ កាលហ្នឹងកំលាំងគេវ៉ៃហើយនៅប្រចាំការហ្នឹងឯង កំលាំងទាហានខ្មែរកំលាំងវៀតណាម អីគេនៅហ្នឹងគេប្រចាំការហ្នឹង ។

ប៊ុនថនៈ វ៉ៃកាលហ្នឹងមានស្លាប់មានអីទេមីង?

ធីមៈ អូយ!មានស្លាប់ច្រើនណាស់ ស្លាប់ច្រើនតែម្តង ។

ប៊ុនថនៈ ស្លាប់ខាងណា?

ធីមៈ ស្លាប់ទាហានខាងហ្នឹងក៏ស្លាប់ទាហានខាងយើងក៏ស្លាប់ ស្លាប់រៀងៗខ្លួន ។

ប៊ុនថនៈ កាល៨៤ហ្នឹងមីង?

ធីមៈ ចាស ។

ប៊ុនថន:	ចឹងមីងកាល៨៦មីងលែងដឹងនៅហ្នឹងហើយ?

ធីម:	ចាស!លែងដឹងនៅហ្នឹងហើយមកនៅនេះហើយ ។

ប៊ុនថន:	ចឹងមីងការហើយមកនៅនេះតែម្តង?

ធីម:	ចាស ។

ប៊ុនថន:	ចឹងពូមកនៅហ្នឹងដែរ?

ធីម:	ចាស!មកនៅទាំងអស់គ្នា ។

ប៊ុនថន:	ចឹងកាលមីងនៅជំរំ៨៥ហ្នឹងខ្មែរយើងជាអកគ្រប់គ្រង់ឬមួយថៃគ្រប់គ្រង?

ធីម:	ខ្មែរយើងគ្រប់គ្រង ។

ប៊ុនថន:	និយាយថាភាគច្រើនកងទ័ពឬប្រជាជនយើងជំរំហ្នឹង?

ធីម:	ជំរំហ្នឹងសុទ្ធជំរំកងទ័ព តែត្រង់ថាប្រពន្ធគេនៅហ្នឹងចឹងទៅ ទ័ពគេមកនៅប្រចាំការព្រំដែន ។

ប៊ុនថន:	មកប្រចាំការព្រំដែន?

ធីម:	ចាស!ភាគច្រើនមានតែប្រពន្ធទ័ព ។

ប៊ុនថន:	ចុះពូប្រុសៗអីគេមានឲ្យមកប្រចាំការទេ?

ធីម:	មក ។

ប៊ុនថន:	មកនេះដែរ?

ធីម:	ចាស ។

ប៊ុនថន:	ចឹងមីងនៅខាងក្នុងទៅពូមកខាងនេះ?

ធីម:	ចាស ។

ប៊ុនថន:	ចឹងស្បៀងអីបើកឬមួយយ៉ាងម៉េច?

ធីម:	បើកគេចែក សម្បូរហូបតែអួន សម្បូរហូបណាស់ នៅនេះឃ្លាំងអង្ករ សម្ភារៈមានពេញ ឃ្លាំង"ប្តីគាត់និយាយ"ឡានថៃដឹកមកចឹងពីរបីឡានកង់ដប់មាន៤០០បាវអីមក១០០០ បាវចឹងយកមកដល់ដាក់ឃ្លាំងចឹង ដល់ខែចឹងហៅប្រជាជនទ័ពប្រពន្ធទ័ពហ្នឹងមកបើក ។

ប៊ុនថន:	បាទ ។

ធីម:	ក្នុងមួយខែបើកម្តង ។

ប៊ុនថន:	ដឹកចូលមកដល់ដីខ្មែរឬដីថៃ?

ធីម:	ដឹកពីថៃមក ។

ប៊ុនថន:	ឃ្លាំងគេនៅម្តុំណា?

ធីម:	ឃ្លាំងគេនៅកន្លែងគយហ្នឹង កន្លែងក្រោយផ្ទះខ្ញុំក៏កន្លែងឃ្លាំងដែរ ។

ប៊ុនថន៖ ចឹងនិយាយរបបអត់មានខ្វះទេ?

ធីម៖ ចាស!ស្លាប់ច្រើនដែរ ។

ប៊ុនថន៖ មានស្លាប់ច្រើនដែលពូ?

ធីម៖ ស្លាប់និងឈឺតែម្តង ។

ប៊ុនថន៖ ចឹងឆ្នាំ៨៦ពូមកដល់នេះ?

ធីម៖ ឆ្នាំ៩០បានខ្ញុំមកដល់នេះ ។

ប៊ុនថន៖ ចឹងពូពិការដោយសារអីវិញពូ?

ធីម៖ ខ្ញុំពិការដោយសារមីន មីនយួនកាលខ្ញុំដើរធ្វើការទៅជាន់ តាំងកូនពៅខ្ញុំនៅតូច ។

ប៊ុនថន៖ ចឹងដាក់ជើងហើយមានត្រូវកន្លែងណាទៀតទេ?

ធីម៖ អត់មានត្រូវកន្លែងណាទេ ត្រូវតែជើង ។

ប៊ុនថន៖ តែឥឡូវមានធ្វើទុកអីទេ?

ធីម៖ អត់អី ។

ប៊ុនថន៖ ធម្មតា?

ធីម៖ ធម្មតា យើងដាច់ជើងចេះយើងធ្វើការមិនដូចជើងយើងនៅពេញទេ វាពិបាក ។

ប៊ុនថន៖ ចឹងមីងនៅជំរំរហូត ដល់កូនធំៗហើយមីងមានមកហ្នឹងវិញទេ?

ធីម៖ កាលហ្នឹងខ្ញុំមានកូនតែពីរ មានមីមួយនេះនិងអាបងគេរៀននៅស្វាយ ។

ប៊ុនថន៖ ចឹងមីងនៅហ្នឹងរហូតដល់៩០បានមកនេះ?

ធីម៖ ចាស!ឆ្នាំ៩០បានមកនៅនេះ ។

ប៊ុនថន៖ មកដល់ដំបូងគេចែកដីឬមួយមីងមកនៅ?

ធីម៖ អត់មកដល់យើងចាប់ ។

ប៊ុនថន៖ ចាប់ដីនៅពល់ថ្ងៃហ្នឹងមីង?

ធីម៖ ចាស!យើងរាវមីនចាប់ ។

ប៊ុនថន៖ ដីហ្នឹងដល់ក្រោយទេមីង?

ធីម៖ ដីខ្ញុំដល់ក្រោយ តែខាងក្រោយឲ្យគេនៅសិនទៅហើយគេនៅរហូតចឹងទៅនៅសល់ដីខ្ញីចឹង ទៅ ។

ប៊ុនថន៖ ចឹងបានត្រឹមរបងហ្នឹង?

ធីម៖ ចាស ។

ប៊ុនថន៖ ធំដែលតើ?

ធីមៈ ហើយពីនេះទៅដល់នោះត្រឹមបង្គោលខ្សែភ្លើង ហើយនៅនោះមួយកន្លែងទៀតដីធំនោះសុទ្ធដើមឈើ ។

ប៊ុនថុនៈ បាទ ។

ធីមៈ ដាំស្វាយដាំដូងចោលទៅ ។

ប៊ុនថុនៈ បើធ្វើដូះល្វែងបានច្រើនល្វែង?

ធីមៈ ចាស ។

ប៊ុនថុនៈ ដីចាប់បានប៉ុន្មានយកប៉ុណ្ណឹងឬមានកំណត់ដែរ?

ធីមៈ ចាស! យើងកាប់បានយកទៅ ។

ប៊ុនថុនៈ ហើយមានកំលាំងច្រើនក្រោយបានប៉ុន្មានយកប៉ុណ្ណឹងទៅ?

ធីមៈ ហ្នឹងហើយ កាលហ្នឹងខ្ញុំពិការហើយមានបានប៉ុន្មាន ។

ប៊ុនថុនៈ ចឹងមានដីចំការដែលពូ?

ធីមៈ អត់ ចេះតែរកស៊ីដូរ្វារបន្តិចបន្តួចចឹងទៅ ។

ប៊ុនថុនៈ ចឹងឆ្នាំ៩០មានវ៉ៃគ្នាខ្លះទេ?

ធីមៈ ឆ្នាំ៩០មាននៅវ៉ៃ វ៉ៃដល់ឆ្នាំ៩៦ ។

ប៊ុនថុនៈ ចឹងពេលវ៉ៃមីងធ្វើយ៉ាងម៉េចទៅ?

ធីមៈ វ៉ៃចឹងទៅ ទៅនៅខ្វាងរាប់នោះ កន្លែងសមរភូមិហើយកាលហ្នឹង កន្លែងសមរភូមិខ្វាងរាប់នៅត្រង់នេះមិនអីទេ ។

ប៊ុនថុនៈ ចឹងពីនេះទៅខ្វាងរាប់ហ្នឹងមានចំងាយប៉ុន្មានគីឡូ?

ធីមៈ ចម្ងាយ៤០គីឡូ ។

ប៊ុនថុនៈ ឆ្ងាយដែលដ្បោងក៏ដ្បោងមិនដល់ដែរ?

ធីមៈ ដ្បោងមិនដល់ទេ បានតែឮសម្លេងត្រឹមៗ ឃើញភ្លើងនៅពេលល្ងាច ។

ប៊ុនថុនៈ ចឹងខ្លាចទេមីង?

ធីមៈ កាលហ្នឹងធម្មតាយើងអ្នកធ្វើសង្គ្រាមហើយឮគ្រាប់ចឹងៗទៅលែងខ្លាចលែងញញើតហើយ ឆ្អិនហ្នឹងគ្រាប់ហើយ ដូចជាថៃវ៉ាវ៉ៃអីមិនមានខ្លាច ឃើញគេផ្ទើលអីឮចេះចុះគេត្រៀមអីតែមីងមិនដែលផ្ទើលហ្នឹងគេទេ រៀបចំតវ៉ាន់អីទេ ។

ប៊ុនថុនៈ ចឹងមីងគិតថាធម្មតា?

ធីមៈ ចាស! ធម្មតាទៅធ្វើសង្គ្រាមយូរគិតថាលែងភ័យលែងខ្លាច ។

ប៊ុនថុនៈ មានអ្នកខ្លះខ្លាចវ៉ៃគ្នានៅថៃខ្មែរហ្នឹងរត់ពេញហ្នឹង?

ធីមៈ	រត់ផ្អើលខ្លាចស្លាប់ ទៅឡានបុកស្លាប់ ខ្លាចគ្រាប់កាំភ្លើងទៅជួបឡានបុកម៉ូតូបុក ពួកចាស់ហ្នឹងមានពីណាទៅមួយអត់ ។

ប៊ុនថនៈ	បាទ ។

ធីមៈ	ខ្លះទុកនៅផ្ទះម្នាក់ចឹងទៅ រត់ទៅអស់ទុកតែម្នាក់នៅផ្ទះទេ បើសភាពការណ៍គេឲ្យទៅយើងទៅៗ បើគេមិនឲ្យទៅទេយើងនៅហ្នឹងទៅ យើងស្តាប់មើលសភាពការណ៍ កាលណាស់ភាពការណ៍ល្អយើងចេះតែនៅទៅ ។

ប៊ុនថនៈ	បាទ ។

ធីមៈ	បើគេថាសភាពការណ៍មិនស្រួលទេ យើងក៏ទៅតាមលក្ខ័ណ្ឌចឹងទៅ ។

ប៊ុនថនៈ	ចឹងមីងមកនៅហ្នឹងមានរបបគេបើកដដែលមីង ឆ្នាំ៨០ ?

ធីមៈ	ចាស!ឆ្នាំ៨០ ហ្នឹងរបបគេបើក ។

ប៊ុនថនៈ	ចឹងនៅនេះឆ្នាំ៩៣គេបោះឆ្នោតនៅនេះយ៉ាងម៉េចដែរ?

ធីមៈ	កាលឆ្នាំ៩៣ហ្នឹងគេរំសាយខ្លះហើយអន្តភាព គេចាប់ផ្តើមរំសាយហើយឆ្នាំ៩៣ហ្នឹង ។

ប៊ុនថនៈ	បាទ ។

ធីមៈ	ហូបបាយដូចជាយើងធ្វើស្រែចំការខ្លួនឯង ។

ប៊ុនថនៈ	បាទ ។

ធីមៈ	ឈប់មានរបបបើកហើយ ។

ប៊ុនថនៈ	ធ្វើបានប៉ុន្មានហូបខ្លួនឯងទៅ?

ធីមៈ	ចាស ។

ប៊ុនថនៈ	ចឹងហូបតាមរៀងខ្លួនឬយ៉ាងម៉េច?

ធីមៈ	ហូបតាមរៀងខ្លួន ។

ប៊ុនថនៈ	ក៏នៅផ្គត់ផ្គង់សមូលហភាព?

ធីមៈ	អត់ គេចាប់ផ្តើមរំសាយអន្តភាពហើយហ្នឹង ។

ប៊ុនថនៈ	ចឹងពីណាអត់បានធ្វើស្រែអីបានបាយណាហូបទៅ?

ធីមៈ	ណាអត់ ទិញ ទិញអង្ករគេហូបទៅ ។

ប៊ុនថនៈ	មានអ្នករកស៊ីដែលកាលហ្នឹង?

ធីមៈ	មាន ខ្ញុំចាប់ផ្តើមគេបំបែកអស់ខ្ញុំរកស៊ី ខ្ញុំរកស៊ីលើកកវ៉ាន់ចុះឡើងចឹងទៅណាស់ ។

ប៊ុនថនៈ	បាទ ។

ធីមៈ	ចាប់ផ្តើមគេបំបែកមកយើងចាប់ផ្តើមរកស៊ីទៅដោយខ្លួនឯង ។

ប៊ុនថនៈ តែមិនទាន់ផ្ដាច់ចេញពីទ័ពទេ?

ធីមៈ នៅ ដូចថាគេប្រឡេះយើងម្ដងបន្តិចៗចឹងទៅណាស់ ។

ប៊ុនថនៈ បាទ ។

ធីមៈ ដើម្បីឲ្យយើងចេះរកស៊ីខ្លួនឯងណាស់ យើងចេះពឹងពាក់កំលាំងខ្លួនឯង ។

ប៊ុនថនៈ បាទ ។

ធីមៈ យើងពឹងពាក់លើកកំលាំងខ្លួនឯងលែងពឹងពាក់គេ ដូចនេះគេប្រឡេះយើងបន្តិចម្ដងៗដល់យើងរឹងហើយគេផ្ដាច់យើងបណ្ដោយ ។

ប៊ុនថនៈ ចឹងពូពិការជើងតាំងពីឆ្នាំណា?

ធីមៈ ៩១ ។

ប៊ុនថនៈ ៩១?

ធីមៈ “ប្ដូនិយាយបាទ” ។

ប៊ុនថនៈ ជាន់មីននៅណាវិញក្មួយ?

ធីមៈ នៅស្រះខ្មែរសេរី ។

ប៊ុនថនៈ នៅផ្ដុំណាវិញពូ?

ធីមៈ ទៅខាងក្រោយផ្សារហ្នឹងទៀត កាលហ្នឹងសុទ្ធព្រៃឫស្សីកាលហ្នឹង កាលហ្នឹងសុទ្ធព្រៃមិនទាន់មានអី តាមអាផ្លូវយើងហ្នឹង កាលហ្នឹងផ្លូវវាមានជាផ្នែកៗហ្នឹង ។

ប៊ុនថនៈ បាទ ។

ធីមៈ កាលហ្នឹងផ្លូវឡានគេហ្នឹងណាស់ យើងដើរកាលហ្នឹងយើងទៅមើលកន្លែងអីផង យួនវាដាក់មីននៅហ្នឹងយើងមិនបានដឹង ។

ប៊ុនថនៈ បាទ!ផ្ទុះនៅហ្នឹង?

ធីមៈ បាទ!ផ្ទុះនៅហ្នឹង ។

ប៊ុនថនៈ ចឹងកាលឆ្នាំ៩៣ហ្នឹងមានរំសាយ រសាយច្រើនទេមីង?

ធីមៈ ចាស!រំសាយអស់ច្រើន ។

ប៊ុនថនៈ ចឹងអ្នកដែលរំសាយហើយហ្នឹងធ្វើអីវិញទៅមីង?

ធីមៈ គេប្រកបអាជីវកម្មរបស់គេធ្វើស្រែចំការ ធ្វើពោត ធ្វើសណ្ដែកធ្វើស្រែ ។

ប៊ុនថនៈ ចឹងពេលហ្នឹងមាននៅវៃគ្នាដែរ?

ធីមៈ នៅ ។

ប៊ុនថនៈ ចឹងរំសាយហើយអ្នកដែលត្រូវការវៃឡើងមកវៃវិញ?

ធីមៈ ចាស!អន្តភាពទ័ពហ្នឹង ទ័ពនៅមានអន្តភាពរបស់គេ យើងប្រជាជនចឹងទៅគេរំសាយចឹងទៅ តែដំនាន់ហ្នឹងអន្តភាពទ័ពឃ្វាំងគេនៅខ្ទាស់ខាប់ឯនោះទេ "ប្តីនិយាយកាលហ្នឹងអន្តភាពទ័ពមិនទាន់ផ្តាច់ទេ" ។

ប៊ុនថន: តែថាមានរំសាយទេមីង?

ធីមៈ រំសាយហ្នឹងរំសាយតែពួកខ្ញុំអន្តភាពយើងធ្លាប់អន្តរបើកណាស់អាអូន ។

ប៊ុនថនៈ បាទ ។

ធីមៈ ដូចថាយើងធ្លាប់ហូបអន្តរបើក ដល់យើងប្រជាជនអីចឹងទៅគេរំសាយគេឈប់បើកឲ្យយើង ។

ប៊ុនថនៈ បាទ ។

ធីមៈ យើងរកហូបខ្លួនឯងទៅ តែទ័ពគេមានអន្តភាពរបស់គេ តែដូចយើងពិការចេះយើងចូលរួមប្រជាជន យើងរំសាយចេញពីទ័ព ។

ប៊ុនថនៈ រំសាយចេញពីទ័ព អ្នកនៅអត់ពិការអីនៅដដែល?

ធីមៈ ចាស ។

ប៊ុនថនៈ មីងនៅហ្នឹងសមាហរណ៍កម្មហ្នឹងឆ្នាំប៉ុន្មាន?

ធីមៈ សមាហរណ៍កម្មឆ្នាំ៩០ប៉ុន្មានទេ ឆ្នាំ៩០ជាងសមាហរណ៍កម្ម ។

ប៊ុនថនៈ ឆ្នាំ៩៦?

ធីមៈ ហ្នឹងហើយឆ្នាំ៩៦-៩៧ហើយ ៩៧សមាហរណ៍កម្ម៩៧ ។

ប៊ុនថនៈ ចឹងសមាហរណ៍កម្មហើយហ្នឹងនៅមានកងទ័ពអីដដែលមីង?

ធីមៈ មាន ថានៅកងទ័ពមានរហូតដល់សព្វថ្ងៃនេះឯង ។

ប៊ុនថនៈ ពីហ្នឹងមក?

ធីមៈ ចាស!គេអន្តភាពទ័ពគេនៅតែទ័ពដល់សព្វថ្ងៃហ្នឹង លើកលែងថាយើងពិការអីចឹងទៅគេរំសាយចេញពីទ័ពទៅ ។

ប៊ុនថនៈ ចឹងមីងចង់សួរបន្តិចមុនសមាហរណ៍កម្មនិងក្រោយសមាហរណ៍កម្មជីវភាពនិងការរស់នៅរបស់មីងអីខុសប្លែកគ្នាយ៉ាងម៉េចដែរមីង?

ធីមៈ យើងរំសាយពីទ័ពមកយើងធ្លាប់តែហូបអន្តរបើកស្រាប់ តែដល់រំសាយមកយើងពិបាកដែលហ្នឹង ស្រវ៉ានេះផុតស្រវ៉ានោះផុតដែលហ្នឹង ។

ប៊ុនថនៈ ពិបាកយ៉ាងម៉េចទៅមីង?

ធីមៈ យើងពិបាកដែលម្យ៉ាងប្តីយើងពិការចេះទៀតនោះ ពិបាកមិនដឹងធ្វើអីរកអីពិបាក ។

ប៊ុនថន៖ ចឹងជីវភាពអីហ្នឹងយ៉ាងម៉េចដែលមីង អ្នកផ្សេងទៀតមុននិងក្រោយក្រៅពីមីងប្រជាជនផ្សេងទៀត?

ធីម៖ អាហ្នឹងបើគេមានដីមានធ្វើច្រើនទៅគេធ្វើចំការ គេធ្វើទៅគេធូរធារគេទៅ ។

ប៊ុនថន៖ បាទ ។

ធីម៖ យើងដីបន្តិចបន្តួចយើងធ្វើបានតែម៉ាហូប ៗ ។

ប៊ុនថន៖ ចឹងមីងនិយាយថាមានអ្នកអត់ក្រៅពីរំសាយទៅ?

ធីម៖ មាន មានអ្នកអត់មានអ្នកយ៉ាប់ជាងយើងទៀត ។

ប៊ុនថន៖ ចឹងចង់សួរមីងមួយទៀតកាលនៅក្នុងសម័យតស៊ូអីចឹង មីងមានធ្លាប់ជួយអ្នកផ្សេងដូចជាមានអ្នកអីមីងជួយឲ្យរបបអាហារអីឲ្យគេ មីងនៅក្នុងរបបហ្នឹងមីងមានជួយទេ?

ធីម៖ ធ្លាប់ជួយគេដែរ ។

ប៊ុនថន៖ ជួយយ៉ាងម៉េចមីង?

ធីម៖ ជួយថារបៀបយើងមានហូបចុកអីចឹងទៅ គ្នាអត់ចឹងទៅជួយគ្នាដូចជាអង្ករដូចជាអីទៅណាស់ ។

ប៊ុនថន៖ បាទ ។

ធីម៖ ចេះតែជួយចែករំលែកគ្នាហូបទៅ មានប្រហុកអំបិលអីចេះតែចែកគ្នាទៅ ។

ប៊ុនថន៖ ពេលណាវិញកាលហ្នឹងមីង មីងនៅណាវិញ?

ធីម៖ នៅនេះឯង ។

ប៊ុនថន៖ នៅម៉ាឡៃហ្នឹង?

ធីម៖ ចាស ។

ប៊ុនថន៖ ឆ្នាំណាមីង?

ធីម៖ ឆ្នាំ៩១-៩២ចឹងទៅណាស់ ចុះយើងជំនាន់ហ្នឹងមិនទាន់អត់ណាស់ណាទេ ដូចថានៅមានអង្ករហូបអីចឹងទៅណាស់ ។

ប៊ុនថន៖ បាទ ។

ធីម៖ ខ្លះគ្នាអត់ ខ្លះណាគ្នារំសាយមុនយើងចឹងទៅគ្នាអត់ ធ្វើស្រែមិនបានយើងចេះតែជួយទៅចេះតែជួយចែកគ្នាហូបទៅ ។

ប៊ុនថន៖ ចឹងចង់សួរប្រវត្តិមីងដំបូងបន្តិច ពេលមីងចូលរៀនហ្នឹងមីងរៀននៅឆ្នាំណាក្រចេះ?

ធីម៖ នៅស្រុក ។

ប៊ុនថន៖ បាទ ។

ធីមៈ ឆ្នាំ៧៤-៧៥ហើយ ។

ប៊ុនថនៈ ចឹង៧៤ចូលរៀន?

ធីមៈ ចាស ។

ប៊ុនថនៈ រៀនថ្នាក់ទីប៉ុន្មាន?

ធីមៈ កាលហ្នឹងខ្ញុំចូលមកថ្នាក់ទី១ ។

ប៊ុនថនៈ ទី១ចឹងរៀនបានប៉ុន្មានឆ្នាំ?

ធីមៈ មើលរៀនបានដល់ឆ្នាំ៧៧មើលរៀនពីឆ្នាំ៧៤ដល់៧៧ ។

ប៊ុនថនៈ ចឹង៧៧នៅរៀនទៀតមីង?

ធីមៈ ចាស!រៀនទៀត ។

ប៊ុនថនៈ ចឹងឆ្នាំ៧៥រំដោះហើយមែនទេ?

ធីមៈ រំដោះហើយ ។

ប៊ុនថនៈ តែនៅមានសាលារៀនទៀត?

ធីមៈ រៀន ។

ប៊ុនថនៈ រៀនកាលហ្នឹងគ្រួសារមីងមិនទាន់ជម្លៀសទៅណាទេ?

ធីមៈ អត់ទេ ។

ប៊ុនថនៈ នៅភូមិដដែល?

ធីមៈ នៅភូមិដដែល ។

ប៊ុនថនៈ ចឹងរៀនដល់៧៧បានមីងចូលកង?

ធីមៈ ចាស ។

ប៊ុនថនៈ ចូលមកខាងពេទ្យ?

ធីមៈ ពេទ្យ ។

ប៊ុនថនៈ ចឹងឪពុកម្ដាយមីងមានជម្លៀសទៅណាទេ ក្រោយពីមីងចេញមកធ្វើការ?

ធីមៈ អត់ទេ នៅផ្ទះ តែជំនាន់ហ្នឹងគេឲ្យយើងជាប់និន្នាការ ។

ប៊ុនថនៈ បាទ ។

ធីមៈ ពូខ្ញុំធ្លាប់ធ្វើសក្តិពាពីដើម យើងនៅភ្នំពេញ គាត់ធ្វើសក្តិពាដល់ពេលចឹងទៅប្អូនម្ដាយខ្ញុំហ្នឹង ប្ដីគាត់ធ្វើសក្តិពាចឹងជំនាន់ហ្នឹងដូចថាគេដក គេហៅយើងជាប់និន្នាការ ។

ប៊ុនថនៈ បាទ ។

ធីមៈ ជាប់និន្នាការចឹងទៅគេដកផ្ទះដកសំបែង សម្ភាសន៍ដែលប្រើប្រាស់ក្នុងផ្ទះគេដកទាំងអស់ ។

ប៊ុនថនៈ បាទ ។

ធីមៈ ផ្ទះខ្ញុំហ្នឹងគេរើរុះអស់ហើយ គេសង់ផ្ទះតូចឲ្យនៅប្រក់ស្បៅប្រកស្លឹកអីទេ កាលហ្នឹង ។

ប៊ុនថនៈ កាលមុនមីងចេញមកហ្នឹង?

ធីមៈ ចាស!មុនខ្ញុំចេញមកឆ្នាំ៧៥-៧៦ហ្នឹងឯង ។

ប៊ុនថនៈ តែអត់មានជម្លៀសទៅណាទេ?

ធីមៈ ទេ គ្រាន់តែនៅក្នុងភូមិ ។

ប៊ុនថនៈ ចឹងនិយាយថាកាលមីងចេញមកហើយហ្នឹងមានបានទទួលដំណឹងពីម្ដាយមីងទេ?

ធីមៈ អត់ទេ អត់ដែលទទួលដំណឹងអីទាល់តែសោះ ។

ប៊ុនថនៈ ចឹងមីងចេញមកកាល៧៦?

ធីមៈ ចាស!កាលដែលខ្ញុំបានដឹងដំណឹងឆ្នាំ៨៤-៨៥ហើយ ដឹងដំណឹងថាគាត់ស្លាប់ ។

ប៊ុនថនៈ ដឹងតាមពីណាវិញ?

ធីមៈ ដឹងតាមទ័ព ទ័ពគេនៅភូមិខ្ញុំហ្នឹង គេចូលទៅដល់ភូមិ ។

ប៊ុនថនៈ បាទ ។

ធីមៈ ចាស!ដល់ពេលគេបានដំណឹងចឹងទៅ គេមកប្រាប់ថាឪពុកម្ដាយឯងស្លាប់ហើយ ។

ប៊ុនថនៈ ចឹងឆ្នាំ៨០ប៉ុន្មានមីងដឹង?

ធីមៈ ឆ្នាំ៨៤ ។

ប៊ុនថនៈ ចឹងឆ្នាំ៨៤?

ធីមៈ ចាស!ហ្នឹងបានដឹងដំណឹងម្ដាយ តាំងពី៧៨មករហូតមិនដែលបានដឹងដំណឹងឪពុកម្ដាយ យ៉ាងម៉េចមិនបានដឹងទេ ។

ប៊ុនថនៈ បាទ!ចឹងបែកគ្នារហូត?

ធីមៈ បែកគ្នារហូត ហើយម្ដាយឪពុកហ្នឹងថាយើងស្លាប់អស់ហើយ កូនស្លាប់ហើយមិនរស់ទេ ។

ប៊ុនថនៈ ចេញតែមីងម្នាក់តែក្នុងគ្រួសារ?

ធីមៈ គ្រួសារហ្នឹងមើលខ្ញុំចេញពីរនាក់បងប្រុសខ្ញុំ បងបន្ទាប់ខ្ញុំហ្នឹងគេបញ្ជូនទៅ កាលជំនាន់ហ្នឹង គេហៅបូព៌ា ខាងស្វាយរៀង គេបញ្ជូនទៅទល់ដែនហ្នឹង បងប្រុសបន្ទាប់ខ្ញុំហ្នឹងហើយខ្ញុំមក ខាងលិចមក ខ្ញុំបែកគ្នាពីរនាក់បងប្អូន ។

ប៊ុនថនៈ បាទ!ចឹងបងមីងនៅរស់ទេ?

ធីមៈ ស្លាប់ហើយ ស្លាប់កាលឆ្នាំ៩៨-៩៧មុនសមាហរណ៍កម្មយើងនៅវៃគ្នាប្រទង់ប្រទាញ នោះ យើងមុនផ្ដាច់ខ្លួនហ្នឹង ។

ប៊ុនថន: មុនផ្ដាច់ខ្លួន៩៦?

ធីម: ចឹង៩៦ហ្នឹងដឹង ប្ដីគាត់និយាយថា«៩៥»និយាយរួម៩៥ ។

ប៊ុនថន: ចឹងបងប្អូនផ្សេងៗទៀតគាត់នៅក្របេះដដែលទេមីង?

ធីម: មកនៅប៉ៃលិនអស់ហើយ បងប្អូនមកនៅប៉ៃលិនអស់ហើយនៅតែប្អូនស្រីមួយមកនៅក្របេះ ។

ប៊ុនថន: ចឹងថាបងមីងទៅយកមីងនៅឧត្ដរមានជ័យនោះ?

ធីម: ចាស!ឥឡូវគាត់មកនៅប៉ៃលិន ។

ប៊ុនថន: ចឹងគាត់ហ្នឹងគាត់ធ្វើទ័ពដែរ?

ធីម: ចាស!គាត់ធ្វើទ័ពតែឥឡូវគេឲ្យគាត់ធ្វើមេភូមិ ។

ប៊ុនថន: តែគាត់ចេញក្រោយមីង?

ធីម: គាត់ហ្នឹងនៅអង្គភាពទ័ព គាត់ចេញមុនគាត់នៅអង្គភាពទ័ព ។

ប៊ុនថន: ចឹងបងប្អូនមីងចេញធ្វើទ័ពប៉ុន្មាននាក់?

ធីម: បងប្អូនខ្ញុំចេញធ្វើទ័ពច្រើនណាស់ បីបួននាក់នោះ បងប្រុស ។

ប៊ុនថន: បាទ ។

ធីម: ធ្វើទ័ពទាំងអស់តែស្លាប់អស់ពីរហើយទ័ព ស្រីៗស្លាប់អស់ពីរដែរ ។

ប៊ុនថន: ចឹងតាំងពីចេញមីងមាននឹកផ្ទះដែរ?

ធីម: នឹកៗ យប់ឡើងដេកយំថ្ងៃណាក៏ដេកយំដែរ មកនៅ១០២ហ្នឹងហើយសុំគេទៅផ្ទះវិញគេថាមិនបាច់ទៅទេ គេថាបីខែហ្នឹងត្រូវរូវគ្នាគេចូលទៅនៅស្រុកយើងវិញហើយ សូម្បីតែអ្នកភូមិខ្ញុំគេបបួលទៅស្រុកក្រៅខ្ញុំមិនទៅផង ។

ប៊ុនថន: ចឹងមានអ្នកចេញទៅក្រៅដែរ?

ធីម: ទៅ ។

ប៊ុនថន: មានចេញទៅច្រើនទេមីង?

ធីម: ចឹកហួតនៅភូមិខ្ញុំហ្នឹងគាត់មកបង្រៀនភាសាចិននៅភ្នំពេញហ្នឹងគាត់បបួលខ្ញុំទៅស្រុកក្រៅ ហើយមីងថាមិនឲ្យទៅទេ ឯងទៅធ្វើអីប្រយ័ត្នគេយកទៅលក់ ។

ប៊ុនថន: បាទ ។

ធីម: ខ្ញុំថាមិនអីទេ បងហ្នឹងរាប់អានខ្ញុំទេ ខ្ញុំស្គាល់គ្នាទេ គាត់ខ្លាចយកទៅធ្វើបាប ។

ប៊ុនថន: ចឹងហួត?

ធីម: ចឹកហួតហ្នឹងឥឡូវគាត់នៅខាង«សេឌីកាល់» ។

ប៊ុនថនៈ សេឌីកាត?

ធីមៈ សេឌីកាល់ ប្រទេសសេឌីកាល់ ។

ប៊ុនថនៈ គាត់ទៅធ្វើការនៅហ្នឹង?

ធីមៈ ចាស! គេទៅនៅហ្នឹងដូចថាជនភាសខ្លួនគេទៅនៅហ្នឹង ។

ប៊ុនថនៈ គាត់ទៅនៅយូរហើយ?

ធីមៈ តាំងពីឆ្នាំ៧៩ គាត់ទៅខ្ញុំមិនទៅ ។

ប៊ុនថនៈ ពេលដែលមីងមកនៅម៉ាឡៃហ្នឹង?

ធីមៈ ចាស ។

ប៊ុនថនៈ ចឹងកាលហ្នឹងគាត់ធ្វើអីដែលមីង?

ធីមៈ គាត់បង្រៀនខាងភាសា ។

ប៊ុនថនៈ ភាសាចិន?

ធីមៈ ចាស ។

ប៊ុនថនៈ បង្រៀននៅភ្នំពេញ?

ធីមៈ នៅភ្នំពេញ ។

ប៊ុនថនៈ ចឹងពីមុនមកមីងមានស្គាល់គាត់ទេ?

ធីមៈ គាត់នៅភូមិជាមួយ ។

ប៊ុនថនៈ នៅក្រចេះជាមួយមីង?

ធីមៈ ចាស!ភូមិជាមួយគ្នាផ្ទះជិតគ្នា គាត់មកឃើញខ្ញុំចឹងគាត់ខ្លាចស្លាប់ ។

ប៊ុនថនៈ បាទ ។

ធីមៈ គាត់ថាទៅក្រៅជាមួយបង ខ្ញុំថាខ្ញុំមិនទៅខ្ញុំនឹកម៉ែនឹកឪខ្ញុំមិនទៅទេ ខ្ញុំសួរថាបងទៅហ្នឹងខ្ញុំបានមកលេងឪពុកម្ដាយខ្ញុំវិញអត់ គាត់ថាមកលេងបានតើ អូនឯងចង់មកលេងបាន គាត់ថាមកៗទៅ ។

ប៊ុនថនៈ បាទ ។

ធីមៈ ដល់ពេលចឹងទៅយើងស្ដាប់ពាក្យមេដឹកនាំយើងច្រើនពេក ខ្ញុំមិនហ៊ានទៅខ្លាច ។

ប៊ុនថនៈ បាទ ។

ធីមៈ គេថាចេះថាចុះទៅយើងខ្លាចណាស់ យើងខ្លាចម៉ារហូតណាស់ ខ្លាចមិនបានទៅជួបម្ដាយវិញទៅក៏អត់ទេ ។

ប៊ុនថនៈ ចឹងគាត់នៅសេឌីកាល់គាត់មានដែលមកលេងទេ?

ធីមៈ អត់ អត់ដែលមក ។

ប៊ុនថនៈ បងប្អូនគាត់ទៅទាំងអស់?

ធីមៈ បងប្អូនគាត់នៅក្រចេះ នៅរកស៊ីក្នុងផ្សារក្រចេះ ។

ប៊ុនថនៈ ចឹងនៅពេលដែលមីងបានទទួលដំណឹងថាឪពុកម្ដាយមីងស្លាប់ហើយមីងចង់ទៅស្រុកវិញទេ ?

ធីមៈ ទៅក៏យើងទៅមិនកើត ចង់ទៅតែយើងទៅមិនកើតជំនាន់ហ្នឹងដល់ពេលយើងចេះមកហើយ ម្យ៉ាងដូចជាខ្លាច ខ្លាចតែម្ដង ។

ប៊ុនថនៈ ខ្លាចយ៉ាងម៉េចវិញមីង?

ធីមៈ ខ្លាចទៅចឹងទៅគេចាប់បានចាប់អី ចាប់ធ្វើបាបយើងចឹងទៅណាស់ គេថាយើងខ្មែរក្រហមចឹងទៅណាអូន ។

ប៊ុនថនៈ បាទ ។

ធីមៈ កាលហ្នឹងជាពាក្យឃោសនា បើយើងទៅក៏វាមិនអីដែរ តែយើងស្ដាប់ពាក្យឃោសនាថាគេមិនចង់ឲ្យយើងទៅតែម្ដង ខ្លាចយើងរត់ចោលអន្តភាពចឹងទៅណាស់ ។

ប៊ុនថនៈ បាទ!កាលហ្នឹងមីងនៅឧត្តរមានជ័យ?

ធីមៈ ចាស!នៅឧត្តរមានជ័យ ។

ប៊ុនថនៈ បងប្អូនមីងមានបាត់បង់អីដែលមីង?

ធីមៈ មានស្លាប់អស់៥នាក់ហើយ ហើយសព្វថ្ងៃនៅតែ៥នាក់ទេ ស្រីពីរប្រុសបីនាក់ ។

ប៊ុនថនៈ ស្រីពីរប្រុសបី?

ធីមៈ ចាស ។

ប៊ុនថនៈ ស្លាប់ហ្នឹងសុទ្ធតែទ័ព?

ធីមៈ ទ័ពហ្នឹងស្លាប់៤នាក់ តែម្នាក់ហ្នឹងស្លាប់ដោយសារជំងឺ ។

ប៊ុនថនៈ ចឹងសព្វថ្ងៃនេះនៅក្រចេះម្នាក់ មីងនៅប៉ៃលិនអូសនៅម៉ាឡៃ?

ធីមៈ នៅប៉ៃលិន៣នាក់នៅស្រុកម្នាក់នៅនេះខ្ញុំម្នាក់បែកគ្នាមិននៅជុំគ្នាទេ ។

ប៊ុនថនៈ ចឹងមីងមានដែលទៅក្រចេះលេងទេ?

ធីមៈ ខ្ញុំទៅ ខ្ញុំទៅទើបមកឆ្នាំហ្នឹងខ្ញុំទៅ ។

ប៊ុនថនៈ ទើបទៅម្ដងទេ?

ធីមៈ ទៅញឹកដែលហើយ ច្រើនដងហើយ ។

ប៊ុនថនៈ ទៅប៉ុន្មានដងហើយ?

ធីមៈ បើឪវាខស្សាហ៍បានទៅ កាលម៉ែនៅរស់ ម៉ែគាត់នៅរស់គាត់ខស្សាហ៍បានទៅខ្ញុំទៅបានពីរដង ។

ប៊ុនថន: ចឹងតាំងពីបែក៧/៨មកបានទៅបានពីរដងទេ?

ធីមៈ ចាស ។

ប៊ុនថន: ចឹងកាលទៅហ្នឹងមាននៅស្គាល់បងប្អូនអីទេ?

ធីមៈ ស្គាល់ បងប្អូនជីដូនហ្នឹងស្គាល់ទាំងអស់ ។

ប៊ុនថន: ចឹងកាលទៅដំបូងគេស្មានតែមីងស្លាប់ហើយ?

ធីមៈ ចាស! ទៅដល់គេស្មានថាខ្ញុំស្លាប់ គេថាឯងស្លាប់ហើយគ្មានពីណាថាឯងរស់ទេ ។

ប៊ុនថន: ចឹងមីងមានអារម្មណ៍យ៉ាងម៉េចពេលមីងទៅដល់?

ធីមៈ មានអារម្មណ៍សប្បាយពេលជួបជុំបងប្អូនមិត្តភក្តិអី កាលធ្លាប់នៅជាមួយគ្នាពីមុនសប្បាយម្យ៉ាងដែរ តែគ្រាន់ថាយើងទៅមិនបានជួបឪពុកម្តាយណាស់ យើងទៅមិនបានឃើញឪពុកម្តាយយើង ។

ប៊ុនថន: ចឹងមីងមានចង់និយាយបន្ថែមទៀតដែលខ្ញុំមិនបានសួរ?

ធីមៈ មានចង់បន្ថែមអី ។

ប៊ុនថន: ដូចជាប្រវត្តិមីងអី កន្លែងណាដែលមីងចាំ មីងចាប់អារម្មណ៍ជាងគេ មីងនៅតែចងចាំមានលំបាកឬកំសត់អី?

ធីមៈ បើនិយាយរឿងកំសត់នោះវាកំសត់ហើយ ។

ប៊ុនថន: កំសត់យ៉ាងម៉េចវិញ?

ធីមៈ កំសត់ធម្មតាទេ យើងធ្លាប់រស់នៅជាមួយឪពុកម្តាយ យើងបែកពីឪពុកម្តាយមកវាកំសត់ចឹងនឹកស្រុកនឹកទេសដែលហ្នឹង ។

ប៊ុនថន: បាទ ។

ធីមៈ នឹកឪពុកម្តាយតែមិនដឹងថាធ្វើយ៉ាងម៉េច បើយើងឃ្លាតឆ្ងាយពីស្រុកចឹងហើយ ម្យ៉ាងវាពិបាកផ្លូវទៅមក ពិបាកណាស់អូនអើយជំនាន់ហ្នឹងមិនមែនស្រួលដូចឥឡូវទេ

ប៊ុនថន: បាទ ។

ធីមៈ ទោះបីយើងដេកនឹកយ៉ាងណាក៏មិនអាចទៅកើត ។

ប៊ុនថន: ចឹងមីងមានអារម្មណ៍ថាចង់ទៅផ្ទះដែរ?

ធីមៈ ចង់ និយាយពីចង់វិញ ចង់ដេកមិនលក់ទេ នឹកឪពុកនឹកម្តាយជួនកាលដេកយល់សប្តិ ។

ប៊ុនថន: ចឹងមីងកាលហ្នឹងថាជួបតែបងប្រុសម្នាក់ដែលមកយកមីងទេ?

ធីម៖ ចាស ។

ប៊ុនថន៖ ក្រៅពីហ្នឹងមានបានជួបដែលមីង?

ធីម៖ ជួបបងប្រុសបន្ទាប់មួយទៀត ដែលមានអន្លកភាពនៅប៉ៃលិនហ្នឹង ។

ប៊ុនថន៖ បាទ!ចឹងមីងដំណឹងដឹងមកហ្នឹង និយាយថារត់ពីភ្នំពេញមកហ្នឹងជួបបងរហូតតាមផ្លូវ?

ធីម៖ អត់ទេ ទើបមកជួបឆ្នាំ៨០ ជួបគាត់នៅឆ្នាំ៨០ ជួបហ្នឹងមើលគ្នាមិនស្គាល់ទេ គាត់ដូចជាសង្ស័យខ្ញុំ ខ្ញុំក៏សង្ស័យគាត់ ព្រោះខ្ញុំនៅផ្ទះគាត់ចេញចូល ដូចថាចូលជួរជិនាន់ហ្នឹងណាស់ ។

ប៊ុនថន៖ បាទ ។

ធីម៖ ចេញចូលធ្វើបដិវត្តហ្នឹងតាំងពីខ្ញុំនៅតូចៗ ខ្ញុំមិនសូវចំណាំមុខគាត់បាន ដល់ពេលគាត់បែករហូតចឹងមកទៅ ដល់ពេលឃើញគ្នារបៀបថាមុនហ្នឹងស្រដៀងឪពុក សង្ស័យបងហ្នឹងដូចឪពុកខ្ញុំចឹង ចេះតែសង្ស័យតែបងហ្នឹងចេះតែសង្ស័យចឹងណាស់ ។

ប៊ុនថន៖ បាទ ។

ធីម៖ តែមិនបានដឹងថាបងហ្នឹងស្លាប់ឬរស់មិនដឹង ចេះតែមើលគាត់ គាត់ក៏មើលខ្ញុំ ខ្ញុំក៏មើលគាត់ កាលហ្នឹងខ្ញុំនៅរាំសិល្បៈហ្នឹង ច្រៀងរបាំងត្រុត កាលហ្នឹងនៅរាំរបាំត្រុតដល់គាត់ចេះតែពួនដើមឈើមើល ចុះទ័ពគេមើលឡើងច្រើន គាត់ថាប្អូនអញហើយមិនដឹង ដល់ពេលចេញមកឲ្យមិត្តភក្តិទៅសួរ មើលឯងទៅសួរបងពូហ្នឹងបន្តិចមើលមុខដូចបងអញដល់ហើយ សួរឈ្មោះឪពុកម្តាយចឹងទៅ ប្អូនអញហើយមិនបាច់សួរទេ ចឹងទៅក៏បានជួបបងមួយទៅណាស់ ។

ប៊ុនថន៖ បាទ ។

ធីម៖ ចឹងទៅដូចថាយើងបានជួបក្បាលតែឯង បានជួបបងម្នាក់ចឹងទៅវាមានអារម្មណ៍មួយធូរបន្តិច ។

ប៊ុនថន៖ បាទ ។

ធីម៖ វាមិនសូវនឹកឪពុកម្តាយអីប៉ុន្មាន នឹកដែលតែថាបានបងមួយទៅដូចជាឪពុកយើងចឹងទៅណាស់ ។

ប៊ុនថន៖ តែកាលហ្នឹងគាត់ទៅនៅឧត្តរមានជ័យដែរ?

ធីម៖ ទៅឧត្តរមានជ័យ គាត់ហ្នឹងក៏ដើររកខ្ញុំដែរ ឮថាមកពីភ្នំពេញចឹងទៅមានអន្លកភាពនេះមានអន្លកភាពនោះជាចេះតែដើររកទៅ ។

ប៊ុនថន៖ បាទ ។

ធីមៈ សុំមេគេដើររកចឹងទៅ ដល់ជួបទៅក៏នៅជួបជុំបងប្អូនចឹងទៅ គាត់ទើបបែកទៅដែលហ្នឹង ប៉ៃលិនហ្នឹង នៅហ្នឹងជុំគ្នាដែលហ្នឹង ដល់បងប្រុសខ្ញុំមួយហ្នឹងគេយកទៅនៅប៉ៃលិនទៅ ដល់គាត់នៅប៉ៃលិនដល់រាល់ថ្ងៃទៅ ។

ប៊ុនថនៈ ចឹងកាលជួបជំបូងនៅឧត្តរមានជ័យ?

ធីមៈ ចាស ។

ប៊ុនថនៈ ចឹងក្រោយមកជួបបងបន្ទាប់ទៀតដែរ?

ធីមៈ ចាស ។

ប៊ុនថនៈ ចឹងអត់អីទេ ចឹងពូក៏មានអត់មានអីសួរមីងទៀត?

ធីមៈ ចាស ។

ប៊ុនថនៈ អរគុណច្រើនមីង ។

ធីមៈ ចាស ។

**«ចប់»**